ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ១១៦០ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី...ខែវិច្ឆិកា ឆ្នាំ ២០០៨

លិខិតចូល

ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ 20០៨

# ប្រកាសណែនាំ
## ស្តីពី
## ការបិទបញ្ជីចំណូល-ចំណាយ និង ការធ្វើរបាយការណ៍បូកសរុបអនុវត្តចំណូល-ចំណាយថវិការដ្ឋឆ្នាំ ២០០៨

- យោងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ។
- យោងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣៥ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០០៧ ។
- យោងអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើចំណាយថវិការដ្ឋនៅតាមក្រសួង-ខេត្ត-ក្រុង ក្រុងស្វយ័តរាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល ។
- យោងអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ។
- យោងអនុក្រឹត្យលេខ ២០៣ អនក្រ.បក.ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការបែងចែកចំណូលថវិកាទូទៅ របស់រដ្ឋតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ ។
- យោងអនុក្រឹត្យលេខ ២០៤ អនក្រ.បក.ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់ រដ្ឋតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ ។
- យោងប្រកាសលេខ ១៤៤៨ សហវ.ប្រក.ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ ។

ដោយការិយបរិច្ឆេទនៃឆ្នាំថវិកាត្រូវចាប់ផ្តើមពីថ្ងៃទី ០១ ខែ មករា ហើយបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ (មាត្រា ១១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ) ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមធ្វើការណែនាំអំពីនីតិវិធីបច្ចេកទេស ដើម្បីធានាឱ្យការបិទបញ្ជីចំណូល-ចំណាយ និង ការធ្វើរបាយការណ៍បូកសរុបអនុវត្តចំណូល-ចំណាយថវិកាទូទៅរបស់រដ្ឋ ឆ្នាំ ២០០៨ ប្រព្រឹត្តទៅបានត្រឹមត្រូវ និង ទាន់ពេលវេលាដូចតទៅនេះ :

I- <u>អំពីការបិទបញ្ជីចំណូល-ចំណាយថវិការដ្ឋឆ្នាំ ២០០៨</u>

ក-<u>អំពីចំណូលថវិការដ្ឋ</u>

ចំណូលថវិកាទាំងអស់ ទោះបីស្ថិតក្នុងប្រភេទចំណូលណាក៏ដោយ អាណាប័កគ្មានសិទ្ធយកចំណូលយកទៅចំណាយតាមទំនើងចិត្ត ឬ ពន្យាពេលបង់ចូលថវិការដ្ឋ ដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ណាមួយបានឡើយ (ភាគទី III និងមាត្រា១០៦ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ) ។ ដូចនេះ **ប្រាក់ចំណូលទាំងអស់ត្រូវតែប្រមូលបង់ចូលថវិការដ្ឋយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ជាកំហិត ។**

ខ-<u>អំពីចំណាយថវិការដ្ឋ</u>

ការបិទបញ្ជីចំណាយ (មាត្រា ១០៧ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ) ត្រូវដំណើរការទៅតាមដំណាក់កាលចំណាយ និង ពេលវេលាដូចតទៅ :

- **ទិដ្ឋាការនៃការសន្យាចំណាយ** ក្រៅពីចំណាយបៀវត្ស និង ចំណាយសំរាប់គោលនយោបាយសង្គមកិច្ច **មិនអាចអនុវត្តក្រោយថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ បានទេ** (មាត្រា ១០៨ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ១៩៩៥ ) លើកលែងតែករណីមាន**ចំណាយចាំបាច់មិនអាចខានបាន និង មានឥណទានថវិកាទំនេរ** ហើយទិដ្ឋាការនេះត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ( មាត្រា ២០ នៃអនុក្រឹត្យ លេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ) **តែក៏មិនឱ្យហួសពីថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៨ ដែរ ។**

- **រាល់ការសន្យាចំណាយដែលមិនបានចេះផ្សាយអាណត្តិបើកប្រាក់នៅមុនថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ត្រូវបានបដិសេធចោល ហើយត្រូវស្នើសុំធានាចំណាយជាថ្មីដោយប្រើប្រាស់ឥណទានថវិកានៃឆ្នាំបន្ទាប់** (មាត្រា ១០៩ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ) ។

- រតនាគារថ្នាក់កណ្តាល និង រតនាគារថ្នាក់មូលដ្ឋាន **ត្រូវបញ្ឈប់ការទទួលអាណត្តិបើកប្រាក់ត្រឹមវេលាម៉ោង ១៧ និង ៣០ នាទី នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨** ។ ដូច្នេះក្រសួង-ស្ថាប័នត្រូវប្រមូលសក្ខីប័ត្រ និងលិខិតយុត្តិការ ដែលបញ្ជាក់ពីសេវាដែលបានធ្វើរួច ដើម្បីរៀបចំអាណត្តិបើកប្រាក់ ហើយបញ្ជូនទៅឆ្លង**ទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៨** ។ ដោយឡែកមន្ទីរជំនាញខេត្ត-ក្រុង ត្រូវបញ្ជូនអាណត្តិបើកប្រាក់ដែលបានឆ្លងទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ **ទៅអភិបាលខេត្ត-ក្រុងពិនិត្យចុះហត្ថលេខា ឱ្យបានមុនថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៨ ។**

គ-<u>អំពីចំណាយរដ្ឋបាលឃុំសង្កាត់និងថវិកាឃុំសង្កាត់</u>

- **រដ្ឋលេខាធិការ/ឃុំសង្កាត់** ត្រូវប្រមែប្រមូលលិខិតយុត្តិការចំណាយ ដើម្បីធ្វើអាណត្តិនិយ័តកម្ម (ទូទាត់) **យ៉ាងយូរបំផុតក្នុងរយៈពេលមួយខែ** ដោយគិតចាប់ពីកាលបរិច្ឆេទដកសាច់ប្រាក់ពីរតនាគារថ្នាក់កណ្តាល ឬ រតនាគារថ្នាក់មូលដ្ឋាន (មាត្រា ៦៧ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ )

លើកលែងតែក្នុងខែធ្នូនៃឆ្នាំ រតនាគារថ្នាក់កណ្តាល ឬ រតនាគារថ្នាក់មូលដ្ឋាន ត្រូវបញ្ឈប់ការដកសាច់ប្រាក់រង្វាន់លើកទឹកចិត្ត **រង្វាន់មុនប្រេទានចុងក្រោយបង្អស់នៅម៉ោង ១៧ និង ៣០នាទី នាថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៨ ។** ក្នុងរយៈពេលពីថ្ងៃទី **១១ ដល់ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៨** រង្វាន់លើកទឹកចិត្តបុរេប្រទានត្រូវត្រូវប្រមូលឯកសារ និង លិខិតយុត្តិការចំណាយរួចធ្វើអាណត្តិនិយ័តកម្មឆ្លងទិដ្ឋាការអភិបាលហិរញ្ញវត្ថុ ហើយបញ្ជូនទៅរតនាគារថ្នាក់កណ្តាល ឬ រតនាគារថ្នាក់មូលដ្ឋាន យ៉ាងយូរបំផុតត្រឹមថ្ងៃទី **៣១ ខែ ធ្នូ ឆ្នាំ ២០០៨** ជាកំហិត ។ ចំពោះសាច់ប្រាក់រង្វាន់លើកទឹកចិត្តបុរេប្រទានដែលក្រសួង-ស្ថាប័ន មន្ទីរ-អង្គភាព ចំណាយសល់ ត្រូវយកមកបង់នៅរតនាគារថ្នាក់កណ្តាល ឬ រតនាគារថ្នាក់មូលដ្ឋានអោយបានមុនថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ។

- **ថវិកាបុរេប្រទាន** គឺជាការបើកផ្តល់ចំណាយមុន ក្នុងករណីមានការចាំបាច់បន្ទាន់ ដូច្នេះការផ្តល់ថវិកាបុរេប្រទានត្រូវបញ្ឈប់ត្រឹមថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ហើយការទូទាត់ថវិកាបុរេប្រទាននេះក៏ត្រូវត្រូវប្រមូលលិខិតយុត្តិការធ្វើអាណត្តិនិយ័តកម្មសុំទូទាត់ឱ្យបានមុនថ្ងៃទី **៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ។ ក្នុងករណីប្រាក់បុរេប្រទានឆ្នាំ ២០០៨ ដែលមិនបានធ្វើការទូទាត់អស់នោះទេ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនឹងកាត់ទុកឥណទានថវិកាពាក់ព័ន្ធ ក្នុងក្របខ័ណ្ឌថវិកាឆ្នាំ ២០០៩ មុននឹងធ្វើការធានាចំណាយសំរាប់ឆ្នាំ ២០០៩ ។**

ក្នុងករណីមានការខ្វះខាតឥណទានថវិកាសំរាប់ធ្វើការទូទាត់រង្វាន់លើកទឹកចិត្តបុរេប្រទាន ឬ បុរេប្រទាន រង្វាន់លើកទឹកចិត្ត ឬ មន្ត្រីទទួលបន្ទុកត្រូវរាយការណ៍ជាបន្ទាន់ទៅអាណាប័ក ដើម្បីមានវិធានការតាមការជាក់ស្តែង ជាអាទិ៍ :

- លើកសំណើសុំធ្វើនិយ័តភាពថវិកាផ្ទៃក្នុងដែលសល់ទំនេរមកបំពេញឱ្យខ្ទង់ថវិកាដែលត្រូវធ្វើអាណត្តិនិយ័តកម្ម ក្នុងនោះគិតរួមទាំងប្រាក់បុរេប្រទានឆ្នាំមុនៗផង ។
- កាត់បន្ថយ ឬ ផ្អាកជាបណ្តោះអាសន្ននូវទឹកប្រាក់បានធានាចំណាយមួយចំនួនដែលមិនចាំបាច់សំរេចធ្វើការជំរះបញ្ជីចំណាយថវិការង្វាន់លើកទឹកចិត្តបុរេប្រទាន ឬ បុរេប្រទានឱ្យបានជ្រះស្រឡះ ។

ឃ-<u>អំពីចលនាឥណទាន</u>

ការធ្វើ**និយ័តភាពថវិកា**ផ្ទៃក្នុងជំពូកសំរាប់ការទូទាត់ចំណាយចាំបាច់ ឬ ទូទាត់រង្វាន់លើកទឹកចិត្តបុរេប្រទាន ឬ ទូទាត់បុរេប្រទាន **ត្រូវបញ្ឈប់នៅថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៨** ។ ដូច្នេះក្រសួង-ស្ថាប័ន និង មន្ទីរជំនាញតាមខេត្ត-ក្រុងទាំងអស់ត្រូវបញ្ជូនសំណុំលិខិតស្នើសុំនិយ័តភាពឥណទានមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ យ៉ាងយូរបំផុតត្រឹមថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៨ ។

ខ-<u>កិច្ចប្រតិបត្តិការនិយ័តកម្មនៃរតនាគារ</u>

កិច្ចប្រតិបត្តិការនិយ័តកម្មនៃរតនាគារសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ **ត្រូវបន្តរហូតដល់ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៩** (មាត្រា ១១១ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ) ។ កិច្ចប្រតិបត្តិការនេះត្រូវពិនិត្យកត់ត្រាជាលេខនាបន្ថែម ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ដែលទាក់ទងទៅនឹង :

- ការកត់ត្រាជាស្ថាពរនៃចំណូល ឬ ចំណាយដែលបានពិនិត្យកត់ត្រាជាលេខនា មុនថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ជាអាទិ៍ ចូលគណនីកត់ត្រាបណ្តោះអាសន្ន ។

អាណត្តិនិយ័តកម្មដែលទាក់ទងដល់ចំណាយដែលបានបើកផ្តល់ដោយរង្វាន់លើកទឹកចិត្តបុរេប្រទាន និង បុរេប្រទាន មុនថ្ងៃទី ៣១ ខែ ធ្នូ ។

- ការកែតម្រូវលេខនាខុស ។
- កិច្ចប្រតិបត្តិការប្រមូលកិច្ចការពីគណនេយ្យកររង្វាលហិរញ្ញវត្ថុ និង គណនេយ្យកររង នៃរតនាគារថ្នាក់មូលដ្ឋាន ។

<u>ច-កិច្ចប្រតិបត្តិការថវិកាឆ្នាំ ២០០៩</u>

១- ក្នុងករណីមានតម្រូវការចាំបាច់លើការប្រើប្រាស់ឥណទានឆ្នាំ ២០០៩ នៅក្នុងអំឡុងខែ វិច្ឆិកា ឬខែ ធ្នូ ឆ្នាំ ២០០៨ អនុញ្ញាតអោយក្រសួង-ស្ថាប័ន រដ្ឋបាលកណ្តាល និងមន្ទីរជំនាញខេត្ត-ក្រុង ស្នើសុំធានាចំណាយថវិកាសំរាប់ឆ្នាំ ២០០៩ ដោយឈរលើមូលដ្ឋាន ១០០% នៃកញ្ចប់ថវិកា ឆ្នាំ ២០០៩ ដែលបានឯកភាពជាគោលការណ៍ក្នុងពេលពិភាក្សាការពារថវិកាសំរាប់ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ និង ៥០% នៃកញ្ចប់ថវិកាឆ្នាំ ២០០៩ ដែលបានឯកភាពជាគោលការណ៍ក្នុងពេលពិភាក្សាការពារថវិកា សំរាប់ក្រសួង-ស្ថាប័ន ដទៃទៀត និង មន្ទីរជំនាញខេត្ត-ក្រុង ។

២- គំរោងស្នើសុំធានាចំណាយត្រូវធ្វើឡើងចំពោះតែមុខទំនិញ សេវា ឬ ការជួសជុលថែទាំទាំងឡាយណា ដែលមានតំរូវការចំណាយថវិកាច្រើន និង មានតំរូវការជាបន្ទាន់នូវការផ្គត់ផ្គង់ទំនិញ សេវា ឬ ការជួសជុលថែទាំនៅដើមឆ្នាំ ២០០៩ ។

៣- ចាប់ពីថ្ងៃទី **០១** ខែ **មករា** ឆ្នាំ **២០០៩** តទៅ រាល់កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិការដ្ឋឆ្នាំថ្មី ត្រូវកត់ត្រាចូលក្នុងគណនីថវិការដ្ឋឆ្នាំ ២០០៩ ។ ដោយឡែកចំពោះប្រាក់បៀវត្សដែលនៅសល់ពីឆ្នាំ ២០០៨ ហើយយកមកបង់ចូលក្នុងឆ្នាំ ២០០៩ ត្រូវចាត់ទុកថាជាសំណេះចំណាយ ដោយកត់ត្រាបន្ថយលើខ្ទង់ចំណាយប្រាក់បៀវត្សឆ្នាំ ២០០៩ ។

៤- រាល់កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិការដ្ឋឆ្នាំ ២០០៩ ត្រូវផ្អែកលើកម្មវិធីចំណូល-ចំណាយប្រចាំខែ និង ត្រីមាស ដែលក្រសួង-ស្ថាប័ន រដ្ឋបាលកណ្តាល និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវរៀបចំ និង ផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា ) ក្នុងរយៈពេល ០២ សប្តាហ៍ ក្រោយពីច្បាប់ថវិកាត្រូវបានអនុម័ត ។

## II- <u>ការធ្វើរបាយការណ៍បូកសរុបអនុវត្តចំណូល-ចំណាយថវិកានូវទៅរបស់រដ្ឋឆ្នាំ ២០០៨</u>

ការបូកសរុបសម្រេចអំពីការអនុវត្តថវិកាទូទៅរបស់រដ្ឋឆ្នាំ ២០០៨ ត្រូវដំណើរការដូចតទៅ :

- ចាប់ពីថ្ងៃទី **០១** ខែ **កុម្ភៈ** ឆ្នាំ **២០០៩** អគ្គនាយកដ្ឋានរតនាគារជាតិត្រូវដំណើការបូកសរុបកិច្ចប្រតិបត្តិការ រតនាគារទូទាំងប្រទេសអំពីការអនុវត្តចំណូល-ចំណាយថវិការដ្ឋឆ្នាំ ២០០៨ ព្រមទាំងតារាងតុល្យភាពគណនីជាស្ថាពរ មកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ( នាយកដ្ឋានថវិកា ) **យ៉ាងយូរត្រឹម ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៩** ។
- ចាប់ពីថ្ងៃទី **០១** ខែ **មករា** ឆ្នាំ **២០០៩** គ្រប់មន្ទីរជំនាញខេត្ត-ក្រុង ត្រូវធ្វើការផ្ទៀងផ្ទាត់តួលេខអនុវត្តចំណូល-ចំណាយរបស់អង្គភាពខ្លួនឱ្យបានត្រូវគ្នាជាមួយរតនាគារ និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ហើយរៀបចំរបាយការណ៍បូកសរុបអនុវត្តថវិការបស់ខ្លួន រួចផ្ញើមកមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងសាមីចំនួន **០២ច្បាប់ ឱ្យបានមុនថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៩** ។

មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានភារកិច្ចបូកសរុបការអនុវត្តចំណូល-ចំណាយរបស់មន្ទីរជំនាញ នៅខេត្ត-ក្រុង ដែលបានផ្ទៀងផ្ទាត់ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ( អគ្គនាយកដ្ឋានរតនាគារជាតិ និង នាយកដ្ឋានថវិកា ) **ឱ្យបានមុនថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៩ ជាកំហិត** ។

ចំពោះក្រសួង-ស្ថាប័នរដ្ឋបាលកណ្តាល ត្រូវផ្ទៀងផ្ទាត់តួលេខចំណូល-ចំណាយថវិការបស់ខ្លួន ជាមួយអគ្គនាយកដ្ឋានរតនាគារជាតិ នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ ( ចំណាយវិនិយោគដោយហិរញ្ញប្បទាន

ក្រោមឱវាទនៅតាម ខេត្ត-ក្រុងផង រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ( អគ្គនាយកដ្ឋានរតនាគារជាតិ និង នាយកដ្ឋានថវិកា ) **ឱ្យបានមុនថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៩ ជាកំហិត ។**

ចំពោះចំណាយវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស ក្រសួង-ស្ថាប័នត្រូវផ្ទៀងផ្ទាត់តួលេខអនុវត្តជាមួយ អង្គភាពគ្រប់គ្រងគំរោងរបស់ស្ថាប័ននីមួយៗ ហើយរៀបចំរបាយការណ៍បូកសរុបអនុវត្តចំណាយវិនិយោគប្រចាំឆ្នាំ ២០០៨ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ( នាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ និង នាយកដ្ឋានថវិកា ) អោយបានមុនថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៩ ជាកំហិត ។

ក្រសួង-ស្ថាប័ន រដ្ឋបាលកណ្តាល មន្ទីរជំនាញខេត្ត-ក្រុង និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវរៀបចំរបាយការណ៍បូកសរុបការអនុវត្តថវិការបស់ខ្លួន ទៅតាមតារាងគំរូដែលមានភ្ជាប់មកជាមួយនេះ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អោយបានតាមកាលកំណត់ខាងលើជាកំហិតដើម្បីឱ្យក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានលទ្ធភាពធ្វើការបូកសរុបរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៨ ដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសម្រេច និង ស្ថាប័ននីតិបញ្ញត្តិអនុម័ត ឱ្យបានទាន់ពេលវេលា ។

ក្នុងករណីក្រសួង-ស្ថាប័នរដ្ឋបាលកណ្តាល មន្ទីរជំនាញខេត្ត-ក្រុង និងមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ណាផ្ញើរបាយការណ៍ បូកសរុបទូទាត់របស់ខ្លួនមិនបានទាន់ពេលវេលាកំណត់ខាងលើទេ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនឹង យកតួលេខរបាយការណ៍បូកសរុបរបស់អគ្គនាយកដ្ឋានរតនាគារជាតិធ្វើជាតួលេខ ផ្លូវការ ។

គ្រប់ក្រសួង-ស្ថាប័នរដ្ឋបាលកណ្តាល អគ្គនាយកដ្ឋានរតនាគារជាតិ រតនាគារខេត្ត-ក្រុង មន្ទីរជំនាញខេត្ត-ក្រុង និង នាយកដ្ឋានពាក់ព័ន្ធទាំងឡាយ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

<u>**ចម្លងជូន:**</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អាជ្ញាធរសវនកម្មជាតិ
  (ដើម្បីជូនជ្រាបជាព័ត៌មាន)
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
- គ្រប់ក្រសួង-ស្ថាប័នរដ្ឋបាលកណ្តាល
- គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋានពាក់ព័ន្ធ
  ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រតនាគារខេត្ត-ក្រុង
- គ្រប់មន្ទីរជំនាញតាមខេត្ត-ក្រុង
  (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

ក្រសួង: ...............

## តារាងសរុបចំណូលថវិការដ្ឋ
## សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ | អនុវត្តជាក់ស្តែង | សមាមាត្រប្រៀបធៀប | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣=២/១ | |
| | | | I - ផ្នែករដ្ឋបាលកណ្តាល | | | | |
| | | | II- ផ្នែកមន្ទីរជំនាញខេត្ត-ក្រុង | | | | |
| | | | សរុបរួម | | | | |

| | | | |
|---|---|---|---|
| ហត្ថលេខានិងត្រា<br>អគ្គនាយករតនាគារជាតិ | ហត្ថលេខានិងត្រា<br>រដ្ឋមន្ត្រី | ហត្ថលេខា<br>ប្រធានគណនេយ្យ | ហត្ថលេខា<br>អ្នកធ្វើតារាង |

ក្រសួង:..............

## តារាងសរុបចំណាយថវិការដ្ឋ
## សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ | ចលនាឥណទាន | | ស្ថានភាពឥណទានថ្មី | អនុវត្តជាក់ស្តែង | សមាមាត្រប្រៀបធៀប | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | + | - | | | | |
| | | | | ១ | ២ | ៣ | ៤ | ៥ | ៦-៥/៤ | |
| | | | I – ផ្នែករដ្ឋបាលកណ្តាល<br>១. សរុបចំណាយចរន្ត | | | | | | | |
| | | | ២. សរុបចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស | | | | | | | |
| | | | II– ផ្នែកមន្ទីរជំនាញខេត្ត-ក្រុង<br>១. សរុបចំណាយចរន្ត | | | | | | | |
| | | | ២. សរុបចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស | | | | | | | |
| | | | សរុបរួម<br>១. សរុបចំណាយចរន្ត<br>២. សរុបចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស | | | | | | | |

ហត្ថលេខានិងត្រា
អគ្គនាយករតនាគារជាតិ

ហត្ថលេខានិងត្រា
រដ្ឋមន្ត្រី

ហត្ថលេខា
ប្រធានគណនេយ្យ

ហត្ថលេខា
អ្នកធ្វើតារាង

ក្រសួង: .............

## តារាងសរុបចំណាយវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស
## សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨

ឯកតា: ពាន់ដុល្លារអាមេរិក

| លេខគំរោង | ឈ្មោះគំរោង | ប្រភពជំនួយ | ប្រភេទជំនួយ | រយៈពេលអនុវត្តគំរោង | តំលៃគំរោង | គំរោង ឆ្នាំ ២០០៨ | អនុវត្តជាក់ស្តែង ឆ្នាំ ២០០៨ |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| សរុបរួម | | | | | | | |

ហត្ថលេខានិងត្រា
រដ្ឋមន្ត្រី

ហត្ថលេខា
ប្រធានអង្គភាពគ្រប់គ្រងគំរោង

ហត្ថលេខា
ប្រធានគណនេយ្យ

ហត្ថលេខា
អ្នកធ្វើតារាង

ខេត្ត-ក្រុង: ................

មន្ទីរ:........................

## តារាងសរុបចំណូលថវិការដ្ឋ
## សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ដើមឆ្នាំ | អនុវត្តជាក់ស្តែង | សមាមាត្រ ប្រៀបធៀប | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣.២/១ | |
| | | | | | | | |
| | | | សរុបរួម | | | | |

| ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខា | ហត្ថលេខា |
|---|---|---|---|---|
| ប្រធានរតនាគារខេត្ត-ក្រុង | អភិបាលខេត្ត-ក្រុង | ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធានគណនេយ្យ | អ្នកធ្វើតារាង |

ខេត្ត-ក្រុង:..................

មន្ទីរ :.....................

## តារាងសរុបចំណាយថវិការដ្ឋ
## សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ | ចលនាឥណទាន | | ស្ថានភាពឥណទានថ្មី | អនុវត្តជាក់ស្តែង | សមាមាត្រប្រៀបធៀប | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | + | - | | | | |
| | | | | ១ | ២ | ៣ | ៤ | ៥ | ៦.៥/៤ | |
| | | | ១. សរុបចំណាយចរន្ត | | | | | | | |
| | | | ២. សរុបចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស | | | | | | | |
| | | | សរុបរួម | | | | | | | |

| | | | | |
|---|---|---|---|---|
| ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខា | ហត្ថលេខា |
| ប្រធានរតនាគារខេត្ត-ក្រុង | អភិបាលខេត្ត-ក្រុង | ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធានគណនេយ្យ | អ្នកធ្វើតារាង |